# ប្រទេសកម្ពុជា/សិទ្ធិមនុស្សៈ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិបំពេញបេសកកម្មស្វែងរកការពិតជាថ្មី

ហ្សឺណែវ/ភ្នំពេញ (ថ្ងៃទី ៧ ខែ មករា ឆ្នាំ ២០១៤) អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា សុរិយា ស៊ូប៊ែឌី នឹងបំពេញទស្សនកិច្ចជាផ្លូវការមកប្រទេសកម្ពុជាចាប់ពីថ្ងៃទី ១២ ដល់ ថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០១៤។ នេះគឺជាដំណើរទស្សនកិច្ចស្វែងរកការពិតលើកដំបូងរបស់គាត់មកប្រទេសកម្ពុជា ចាប់តាំងពីមានការបោះឆ្នោត។

លោក ស៊ូប៊ែឌី បានមានប្រសាសន៍ថា “បេសកកម្មខាងមុខរបស់ខ្ញុំគឺជាផ្នែកមួយនៃការវាយតម្លៃរបស់ខ្ញុំដែលកំពុងតែធ្វើទៅលើស្ថានការសិទ្ធិមនុស្សនៅប្រទេសកម្ពុជា”។ គាត់បានកត់សំគាល់ថា គាត់នឹងពិនិត្យមើលផងដែរអំពីការរីកចម្រើនដែលបានធ្វើឡើងក្នុងការឈានទៅរកបង្កើតស្ថាប័នសិទ្ធិមនុស្សឯករាជ្យ។

ក្នុងអំឡុងពេលបំពេញបេសកកម្មប្រាំថ្ងៃរបស់គាត់ អ្នកជំនាញការឯករាជ្យនឹងជួបជាមួយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និង សមាជិករាជរដ្ឋាភិបាលជាន់ខ្ពស់ផ្សេងទៀត។ គេរំពឹងថា គាត់នឹងជួបជាមួយអ្នកការពារសិទ្ធិមនុស្ស អ្នកតំណាមកពីអង្គការសង្គមស៊ីវិល និងសហាគមន៍ ព្រមទាំងក្រុមស្ថាប័នអង្គការសហប្រជាជាតិប្រចាំប្រទេស និង សហាគមន៍ម្ចាស់ជំនួយ។

អ្នករាយការណ៍ពិសេសបំពេញដំណើរទស្សនកិច្ចជាទៀងទាត់មកប្រទេសកម្ពុជា និងរាយការណ៍ប្រចាំឆ្នាំទៅក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។ ចាប់តាំងពីគាត់ត្រូវបានតែងតាំងនៅខែមីនា ឆ្នាំ ២០០៩ អ្នកជំនាញការរូបនេះបានបំពេញដំណើរទស្សនកិច្ចចំនួនប្រាំបួនលើកមកហើយមកកាន់ព្រះរាជាណាចក្រកម្ពុជាមកដល់ពេលនេះ ហើយបានដាក់របាយការណ៍ចំនួនប្រាំមួយមកហើយ។

នៅក្នុងរបាយការណ៍ចុងក្រោយរបស់គាត់* លោក ស៊ូប៊ែឌី បានជំរុញឲ្យរដ្ឋាភិបាលកម្ពុជា “បង្កើនល្បឿនដំណើរការកំណែទម្រង់ស្ថាប័នរដ្ឋដែលទទួលបន្ទុកការពារ និង លើកកម្ពស់សិទ្ធិមនុស្ស និង បង្កើនល្បឿនដំណើរការប្រជាធិបតេយ្យនីយកម្មនៃប្រទេសកម្ពុជា ដើម្បីឲ្យអត្ថប្រយោជន៍នៃការរីកចម្រើនសេដ្ឋកិច្ចអាចត្រូវបានបែងចែកដោយស្មើភាពគ្នាដោយអ្នកទាំងអស់គ្នា នៅក្នុងប្រទេស”។

លោក ស៊ូប៊ែឌី នឹងដាក់របាយការណ៍លើកក្រោយរបស់គាត់ទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស ក្នុងកិច្ចប្រជុំដែលប្រព្រឹត្តនៅខែ កញ្ញា ឆ្នាំ ២០១៤។

អ្នករាយការណ៍ពិសេសនឹងធ្វើសន្និសីទកាសែតនៅថ្ងៃព្រហស្បតិ៍ ទី ១៦ ខែមករា ម៉ោង ២ រសៀល នៅការិយាល័យឧត្តមស្នងការរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដែលមានអសយដ្ឋានផ្ទះលេខ ១០ ផ្លូវ ៣០២ សង្កាត់បឹងកេងកង ១ ភ្នំពេញ។

**(*)** សូមមើលរបាយការណ៍ចុងក្រោយរបស់អ្នករាយការណ៍ពិសេស ដាក់ជូនទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស (A/HRC/24/36): http://www.ohchr.org/EN/HRBodies/HRC/RegularSessions/Session24/Pages/ListReports.aspx ។